អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ធម្មាធិបតេយ្យ និង ប្រជាធិបតេយ្យ ។

www.hoksavann.org

ថ្ងៃទី២ សីហា ២០១១



១- ធម្មាធិបតេយ្យ ៖

ពាក្យថា «ធម្មាធិបតេយ្យ» មកពីពាក្យថា ធម្ម + អាធិបតេយ្យ ប្រែថា មានធម៌ជាអធិបតី ឬមានធម៌ជាធំ ។ ពាក្យធម៌ក្នុងទីនេះសំដៅយកពាក្យប្រៀបប្រដៅរបស់ព្រះពុទ្ធដែលនិយាយការពិត ជាសច្ចធម៌ ដែលណែនាំមនុស្សនិងសង្គមមនុស្សទៅរកសុខសន្តិភាព ។ ផ្លូវធម៌នេះជាច្បាប់សកលជាច្បាប់យុត្តិធម៌ ដែលរកឃើញនិងសំដែងដោយព្រះសម្មាសម្ពុទ្ធជាង២៥០០ឆ្នាំមកហើយ ។ ព្រះពុទ្ធដីកាសំដែងយ៉ាងណាហើយ នៅតែការពិតយ៉ាងនោះ ត្រូវគ្រប់ទីកន្លែងនិងគ្រប់កាលៈទេសៈ ដូចជាពាក្យថា កើតចាស់ឈឺស្លាប់ បុណ្យបាបគុណទោស មគ្គផលនិព្វានជាដើម ។

ផ្លូវធម៌ គឺនិយាយពីការពិត ជាតថភាព ការពិតយ៉ាងណានិយាយយ៉ាងនោះ ជាយថាវត្ថុ ជាច្បាប់ពិតសកលទៅតាមពិត ពុំមែននិយាយពីការចូលចិត្តឬតាមជំនឿនោះឡើយ ។ ការយកធម៌ជាធំមានន័យថា មុននឹងធ្វើការងារអ្វីមួយបានគិតពិចារណាថា អំពើដែលបំរុងធ្វើនោះ តើមានខុសផ្លូវធម៌ឬទេ ? បើឃើញថាអំពើនោះត្រឹមត្រូវតាមផ្លូវធម៌ហើយ ទើបសំរេចចិត្តធ្វើ ។ អំពើត្រឹមត្រូវជាផ្លូវធម៌ គឺប្រព្រឹត្តអំពើល្អជាកុសល ជៀសវាងអំពើអកុសល អំពើបៀតបៀនអំពើអយុត្តិធម៌នេះហៅថា «ធម្មាធិបតេយ្យ» យកធម៌ជាធំ ។ ប្រៀបដូចអ្នកគោរពផ្លូវអាណាចក្រពុំហ៊ានប្រព្រឹត្តអំពើណាមួយដែលខុសច្បាប់រដ្ឋ ។ បើនិយាយអំពីសង្ឃកម្មរបស់ព្រះសង្ឃ ដែលបានព្រមព្រៀងគ្នាបំពេញកិច្ចការអ្វីមួយរបស់ព្រះសង្ឃត្រូវសំរេចឡើងដោយមតិភាគច្រើនរបស់ព្រះសង្ឃ ហៅថាសំរេចដោយធម៌ «យកធម៌ជាធំ» ហើយនោះ ក៏ចាត់ជាប្រជាធិបតេយ្យរបស់ព្រះពុទ្ធសាសនាដូចផ្លូវអាណាចក្រដែរ ។

២- ប្រជាធិបតេយ្យ ៖

ពាក្យថា «ប្រជាធិបតេយ្យ» មកពីពាក្យថា ប្រជា + អាធិបតេយ្យ ប្រែថា យកប្រជាពលរដ្ឋជាធំ គឺពោលដល់អំណាចនៃរដ្ឋត្រូវកើតចេញមកពីប្រជាពលរដ្ឋ ។ នៅក្នុងប្រទេសដែលមានប្រជាធិបតេយ្យ គេបានចាត់ចែងឲ្យប្រជាពលរដ្ឋជ្រើសរើសតំណាងរបស់ខ្លួនដែលហៅថាតំណាងរាស្ត្រ ជាអ្នកកាន់នីតិបញ្ញត្តិតាមរយៈការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ រួចហើយជ្រើសរើសរដ្ឋាភិបាលដឹកនាំប្រទេសជាអ្នកកាន់នីតិប្រតិបត្តិ ។ អំណាចមួយទៀត គឺអំណាចតុលាការ ជាស្ថាប័នរកយុត្តិធម៌ជូនប្រជាពលរដ្ឋគ្រប់ឋានៈនៅក្នុងប្រទេស ។ អំណាចទាំងបី គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការត្រូវឲ្យដាច់ពីគ្នាដោយឯករាជ្យរៀងៗខ្លួន ។ បើអំណាចទាំងបីនេះនៅជាមួយគ្នា ការអនុវត្តន៍ពុំមានយុត្តិធម៌ឡើយ គឺជារបបផ្តាច់ការ ។ បានសេចក្តីថា ធ្វើច្បាប់ខ្លួនឯង អនុវត្តច្បាប់ខ្លួនឯង កិច្ចការគ្រប់យ៉ាងសំរេចថាមានយុត្តិធម៌ឬពុំមានយុត្តិធម៌ដោយខ្លួនឯង ។ ឧទាហរណ៍ ចោទមនុស្សដោយខ្លួនឯង សំរេចឲ្យមានទោសដោយខ្លួនឯង យ៉ាងនេះពុំមានយុត្តិធម៌ឡើយ ។ បើនិយាយឲ្យងាយយល់ គឺប្រជាពលរដ្ឋទាំងអស់ពុំអាចទៅកាន់តំណាងខាងនីតិបញ្ញត្តិខាងរដ្ឋាភិបាល និងខាងតុលាការទាំងអស់គ្នាបានទេ គឺត្រូវជ្រើសរើសតំណាងរបស់ខ្លួន ឲ្យទៅធ្វើការជំនួសខ្លួនដូចពោលមកហើយនេះឯង ។ ដើម្បីអនុវត្ត «របបប្រជាធិបតេយ្យ» នេះឲ្យមានប្រសិទ្ធិភាព លុះត្រាតែប្រជាពលរដ្ឋមានសេរីភាពជាមូលដ្ឋានពេញបរិបូណ៌ ព្រោះលទ្ធិប្រជាធិបតេយ្យជាទ្រឹស្តីមួយចែងថា អំណាចរបស់រដ្ឋគ្រប់យ៉ាងត្រូវកើតចេញមកពីប្រជាពលរដ្ឋដែលជាម្ចាស់អំណាច ។

បើគេយកធម្មាធិបតេយ្យរបស់ព្រះពុទ្ធសាសនាប្រៀបធៀបនឹងប្រជាធិបតេយ្យរបស់ផ្លូវអាណាចក្រមានលក្ខណៈដូចគ្នានិងខុសគ្នាដូចតទៅ ៖

១- ដូចគ្នាត្រង់ការសំរេចកិច្ចការធំៗរបស់សង្គម ត្រូវយកតាមមតិភាគច្រើនរបស់សមាជិកដែលបានអនុម័ត ។

២- ខុសគ្នាត្រង់របបប្រជាធិបតេយ្យនៃផ្លូវអាណាចក្រសំរេចតាមមតិភាគច្រើននៃសមាជិកសង្គម ឯមតិភាគតិចត្រូវតែសំរេចតាមមតិភាគច្រើន ។ របបនេះអំណាចទាំងបីធ្វើការមានកំណត់ឆ្នាំ ដើម្បីឲ្យប្រជាពលរដ្ឋពិនិត្យមើលសកម្មភាពធ្វើការតើចំរើនឬពុំចំរើន ហើយប្រជាពលរដ្ឋបញ្ចេញមតិសាជាថ្មី ។ ឯធម្មាធិបតេយ្យរបស់ព្រះពុទ្ធសាសនា បើពិនិត្យមើលកិច្ចការរបស់ព្រះសង្ឃ ដែលហៅថាសង្ឃកម្មដូចជាកឋិនកម្មជាដើម គឺភិក្ខុដែលអាចក្រាលគ្រងកឋិនបាន លុះត្រាតែមានការស្រុះស្រួលយល់ព្រមពីព្រះសង្ឃដទៃទៀតក្នុងអង្គប្រជុំ ហើយព្រះសង្ឃដែលក្រាលគ្រងនោះមានសមត្ថភាពនិងមានគុណសម្បត្តិអាចក្រាលគ្រងធ្វើឲ្យសំរេចកឋិនផង និងញុំាងព្រះសង្ឃឲ្យត្រេកអរផង ទើបឈ្មោះថាប្រកបដោយធម៌ ។ ដូចនេះប្រជាធិបតេយ្យរបស់ព្រះពុទ្ធសាសនាសំរេចតាមមតិភាគច្រើនផង ជាអ្នកមានសមត្ថភាព និងគុណសម្បត្តិផង ។

*　　*

*